**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**លេខ** ...០១៦/១៨....**ក.ប**/សជណមហ

# សេចក្តីជូនដំណឹង

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចេញសេចក្តីជូនដំណឹងលេខ ២៧២ កប/ស. ជ.ណ.ម.ហា ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៧ និងសេចក្តីជូនដំណឹងលេខ០១២/១៨ កប/ស. ជ.ណ.ម.ហា ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៨ ដោយកំណត់យកដំណាច់ខែមីនា និងថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨ ជាឱសានវាទ ក្នុងការពន្យារសុពលភាពបណ្ណ/សៀវភៅការងារជនបរទេស។

ចំពោះករណីនេះ ក្រសួងសូមជម្រាបថា ជាការពន្យារពេលជាលើកទី២ សូមម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន និងជនបរទេស ដែលមិនទាន់បានស្នើសុំពន្យារសុពលភាពបណ្ណ/សៀវភៅការងារជនបរទេសឆ្នាំ២០១៨ តាមរយៈគេហទំព័រ www.fwcms.mlvt.gov.kh សូមរួសរាន់ដើម្បីបញ្ចៀសការផាកពិន័យតាមអត្រាប្រាក់ឈ្នួលយោងប្រចាំថ្ងៃ ៥០ ០០០៛(សែសិបពាន់រៀល)។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាប ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន និងជនបរទេសដែលប្រកបមុខរបរណាមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ជ្រាបថា ក្រសួងនឹងពន្យារពេល សម្រាប់ការស្នើសុំពន្យារសុពលភាពបណ្ណ/សៀវភៅការងារជនបរទេស រហូតដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន និងជនបរទេសដែលប្រកបមុខរបរណាមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ប្រញាប់ស្នើសុំពន្យារសុពលភាពបណ្ណ/សៀវភៅការងារជនបរទេសតាមរយៈគេហទំព័រ www.fwcms.mlvt.gov.kh ឲ្យបានមុនថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨ ជាកំហិត។ ចំពោះការខកខានមិនបានពន្យារសុពលភាពបណ្ណ/សៀវភៅការងារជនបរទេសមុនកាលកំណត់ ក្រសួងនឹងចាត់វិធានការយ៉ាងម៉ឺងម៉ាត់ ជាកពិន័យតាមទោសប្បញ្ញត្តិក្នុងជំពូកទី១៦ នៃច្បាប់ស្តីពីការងារ និងបទប្បញ្ញត្តិជាធរមាន។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សង្ឃឹមយ៉ាងមុតមាំថា ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន និងជនបរទេសទាំងអស់នឹងអនុវត្តតាមសេចក្តីជូនដំណឹងនេះដោយប្រសិទ្ធភាព។

ថ្ងៃ ៣ ១១ កើត ខែពិសាខ ឆ្នាំច សំរិទ្ធិស័ក ព.ស២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៨
**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**កន្លែងទទួល:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រីប្រចាំការ
- ក្រសួងមហាផ្ទៃ
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
  "ដើម្បីជូនជ្រាប"
- គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត
  "ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
- សមាគមនិយោជក "ដើម្បីជ្រាប និងអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទៈ(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩